ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី
លេខ ១៨៥ប្រ
ចុះថ្ងៃទី ០៧ខែកក្កដា ឆ្នាំ១៩៩៩

សាលដីកា
លេខ : ៣៤
ចុះថ្ងៃទី២៤ខែកុម្ភៈឆ្នាំ២០០០

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ឌិត មុន្ទី ប្រធាន
២_ លោក ប៉ែន ស៊ុន ចៅក្រម
៣_ លោក យៀល មួន ចៅក្រម
៤_ លោក សោម សិរីវឌ្ឍ ចៅក្រម
៥_ លោក យស់ សូឡឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក ហេ វ៉ាន់ថន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ២៣៧ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២០១ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ជិន គីមលី ភេទប្រុស អាយុ ៥៥ឆ្នាំ ជាតិ ខ្មែរ មុខរបរលក់ដូរ មានទីលំនៅភូមិ៤ ឃុំលេខ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះជិន ម៉ាង ( ស ) ម្តាយឈ្មោះ គ្រុយ សុខ ( រ ) ប្រពន្ធឈ្មោះ ចាន់ ធារា ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ញៀស ញ៉ុង ភេទស្រី អាយុ ៤៧ឆ្នាំ ជាតិ ខ្មែរ មុខរបរ មេផ្ទះ ទីលំនៅភូមិការ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ឪពុកឈ្មោះ ញៀស ញ៉ៀត ( ស ) ម្តាយឈ្មោះ ណុប ក្រិត ( រ ) ប្តីឈ្មោះ ស្លោក ផន ។

បានផ្ទេរសិទ្ធិឱ្យអ្នកស្រី ឃុត សាលឿន ជាតំណាង ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងបដិសេធ និង ជំទាស់សេចក្តីជូនដំណឹងលក់ឡាយឡុង អចលនៈទ្រព្យ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៩៩ របស់

លោក ជិន គីមលី បានប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចនៃសាលដីកាលេខ ២៣៧ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៨៥ប្រ.ចុះថ្ងៃទី៧ខែកក្កដាឆ្នាំ១៩៩៩ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះជិន គីមលី ថាអចលនទ្រព្យដែលមានបណ្ណសំគាល់លេខឥ.ក០០០០៩០ ចុះថ្ងៃទី ៧-៦-១៩៩៦ របស់នាយកដ្ឋានសុរិយោដី និងJ ,០០១៩ ចុះថ្ងៃទី ២៨-៥-១៩៩៦ របស់ភូមិបាលស្រុកថ្មូនកែវ គឺជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ដែលទិញផ្ទាច់ពីឈ្មោះ អួន ហួត ហៅ យូ សុស មានកិច្ចសន្យាលក់ទិញត្រឹមត្រូវតាមច្បាប់ ហើយខ្លួនកំពុងកាន់កាប់គ្រប់គ្រងសព្វថ្ងៃនេះ ។

អ្នកស្រីញៀស ញ៉ុង បានឆ្លើយថា ខ្លួនបានប្ដឹងឱ្យតុលាការលក់ឡាយឡុងទ្រព្យសម្បត្តិនោះ គឺជាទ្រព្យសម្បត្តិរបស់ឈ្មោះ យូ សុស ហៅ អួន ហួត ដែលតុលាការបានកត់ត្រាទុកជាបណ្ដោះអាសន្ន តាមដីកាសំរេចកិច្ចការប្រញាប់រួចហើយ តែត្រូវបានតុលាការសំរេចផ្អាកការ រឹបអូសជាបណ្ដោះអាសន្ន ដោយអាងថាទ្រព្យសម្បត្តិនេះពាក់ព័ន្ធនិងឈ្មោះជិន គីមលី ប៉ុន្តែការពិតឈ្មោះ យូ សុស បានលក់ផ្ទះនេះទៅឱ្យឈ្មោះជិន គីមលី គឺលក់នៅក្រោយពេលតុលាការកត់ត្រាផ្ទះនេះទុក ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ២៤៧.ស៩៩ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ១៩៩៩ របស់ឈ្មោះ ជិន គីមលី ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បង្គាប់មកមន្ត្រីអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ១២ ខែមិនា ឆ្នាំ ១៩៩៨ ឱ្យផ្អាកជាបណ្ដោះអាសន្ន ការលក់ឡាយឡុងអចលនៈទ្រព្យតាមកំណត់ហេតុរឹបអូសអចលនៈទ្រព្យ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់មន្ត្រីអនុវត្តសាលក្រម នៃតុលាការខេត្តតាកែវជាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសំរេចជាស្ថាពរ នៃរឿងអង្គសេចក្ដី ។

៣- ដីកាសំរេចផ្សេងៗ របស់អនុប្រធានតុលាការខេត្តតាកែវ ដែលផ្ទុយអំពីដីកាសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

- ដីកានេះមានអានុភាពអនុវត្តភ្លាមៗ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩ របស់អ្នកស្រីញៀស ញ៉ុង ដែលប្ដឹងជំទាស់នឹងដីកាសំរេចតាមពាក្យសុំលេខ ២៤៧.ស ៩៩ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ នៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៣៧ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ១៩៩៩ របស់ឈ្មោះ ញៀស ញ៉ុង ទុកជាត្រឹមត្រូវតាមទំរង់ នឹងគតិច្បាប់ ។

២_ បដិសេធដីកាសំរេចកិច្ចការប្រញាប់លេខ ២៤ ពស.៩៩ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ចោលជាអសារបង់ ។

៣_ បង្គាប់ឱ្យអ្នកអនុវត្តសាលក្រម ក្នុងរឿងនេះបន្តអនុវត្តតទៅទៀត តែប្រាក់ដែលបានមកពីការលក់ឡាយឡុង ត្រូវយកតម្កល់ទុកនៅតុលាការ ដើម្បីរង់ចាំទូវការសំរេចពីកាត់វិាចប់ជាស្ថាពរ ។

៤_ វិបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០ រៀល និង អាថ្វាធរតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៥_ សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខនាង ឃុត សាលីន តំណាងនាង ឡេស ញុង និងកំបាំងមុខឈ្មោះ ជិន គីមលី ជាចុងបណ្តឹងឧទ្ធរណ៍ មានអានុភាពអនុវត្ត ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់លោក ជិន គីមលី បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៣១ ចុះថ្ងៃទី១៣ ខែ ឧសភាឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០៨_៩_១៩៩៩ របស់ឈ្មោះ ជិន គីមលី

បានឃើញសារណា ចុះថ្ងៃទី ១២_១០_១៩៩៩ របស់ឈ្មោះ ឡេស ញ៉ុង

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

- ក្រោយពីបានពិនិត្យលើសាលដីការដ្ឋប្បវេណីលេខ ២១៣ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ។
- អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ជិន គីមលី ជាដើមចោទ និងជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : មកពីខ្លួនប្តឹងសាទុក្ខនេះ មកពីសាលាឧទ្ធរណ៍ជំនុំជំរះមិនយុត្តិធម៌ ព្រោះផ្ទះនេះខ្លួនបានទិញមុនដែលតុលាការចុះកត់ត្រាអចលនៈទ្រព្យ ។ នៅពេលទិញហើយ ខ្លួនបានផ្តិតមេដៃចំពោះមុខសុរិយោដី ឃុំ_ស្រុក ហើយបានគ្រប់គ្រងតាំងពីខែ ៩_១៩៩៧ មក ។

ក្រឡាបញ្ជីអានសារណាតបរបស់ឈ្មោះ ឡេស ញ៉ុង

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់លោក ជិន គីមលី និង សារណារបស់អ្នកស្រី ឡេស ញ៉ុង
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៧៨ ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ១៩៩៩ របស់លោក ជិន គីមលី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេច បង្គាប់ឱ្យអ្នកអនុវត្តសាលក្រមបន្តអនុវត្តតទៅទៀត តែប្រាក់បានមកពីការលក់ឡាយឡុងត្រូវយកមកតម្កល់ទុកនៅតុលាការ ដើម្បីរង់ចាំនូវការសំរេចពីការតវ៉ាចប់ជាស្ថាពរ ដោយអាងហេតុថា កិច្ចសន្យាទិញលក់ របស់លោក អួន ហួត និង លោក ជិន គីមលី ធ្វើឡើងក្រោយកំណត់ហេតុអនុវត្តសាលក្រមនោះ ជាការភ័ន្តច្រឡំពីព្រោះថា កំណត់ហេតុអនុវត្តសាលក្រមចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧ ក៏បានបញ្ជាក់ដែរថា ប្លង់ផ្ទះ និងដីរបស់ឈ្មោះ យូ សុស ត្រូវបានដាក់បញ្ញាំឱ្យទៅឈ្មោះ ងោ ហោរី តាំងពីខែ ៩ ឆ្នាំ ១៩៩៧ មកគឺមុនការដែលតុលាការ ធ្វើការកត់ត្រាទ្រព្យសម្បត្តិរបស់ឈ្មោះ យូ សុស ដូច្នេះការឱ្យលក់ទ្រព្យសម្បត្តិនេះនឹងធ្វើឱ្យបាត់ភាពដើម នៃវត្ថុទំនាស់។

- យល់ឃើញថា អ្នកស្រី ញ៉ៀស ញ៉ុង បានធ្វើសារណាការពារផលប្រយោជន៍របស់អ្នកស្រីជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែអ្នកស្រីពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ ២៣១ ចុះថ្ងៃទី ១៣-៥-៩៩ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខលោក ជិន គីមលី កំបាំងមុខអ្នកស្រី ញ៉ៀស ញ៉ុង ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់លោក ជិន គីមលី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីកាវិនិច្ឆ័យលេខ ២៣១ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បញ្ជូនសំណុំរឿងលេខ ១៨៥ប្រ. ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅតុលាការខេត្តតាកែវ ដើម្បីបញ្ចូលក្នុងសំណុំរឿងអង្គសេចក្តី ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន១៩.០០០រៀល ដែលលោក ជិន គីមលី បានបង់រួចហើយគឺៈ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជាររង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

ហើយតម្រូវឱ្យអ្នកស្រីញ៉ៀស ញ៉ុង សងប្រាក់១៩.០០០រៀលនេះ ទៅលោកជិន គីមលី វិញ។

៥_ សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ ។